# ព្រះរាជក្រឹត្យ

នស/រកត/១០១៤/១១៧៤

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានកែសម្រួល និងបន្ថែមសមាសភាព នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ៖

| | |
|---|---|
| ១- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ជាប្រធាន |
| ២- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ជាអនុប្រធាន |
| ៣- ឧបនាយករដ្ឋមន្ត្រីប្រចាំការ | ជាអនុប្រធាន |
| ៤- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ៥- រដ្ឋមន្ត្រីក្រសួងផែនការ | ជាសមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL

៧- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាសមាជិក
៨- រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍជនបទ ជាសមាជិក
៩- រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ជាសមាជិក
១០- រដ្ឋមន្ត្រីក្រសួងសុខាភិបាល ជាសមាជិក
១១- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាសមាជិក
១២- រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ជាសមាជិក
១៣- រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ជាសមាជិក
១៤- រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ជាសមាជិក
១៥- រដ្ឋមន្ត្រីក្រសួងបរិស្ថាន ជាសមាជិក
១៦- រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០២ រូប ជាសមាជិក
១៧- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ រូប ជាសមាជិក
១៨- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ០១ រូប ជាសមាជិក
១៩- អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១រូប ជាសមាជិក
២០- ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសមាជិកអចិន្ត្រៃយ៍ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសមាសភាពដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៥-១៤១០. ១១៩៥

ធ្វើនៅព្រះបរមរាជវាំង. ថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៤

លេខ: ១២០៤ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ .ថ្ងៃទី ០៦ ខែ ១១ ឆ្នាំ២០១៤
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**